**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្ដីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (**ស.ភ.ន.វ.ស.**) ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពការងារអប់រំបណ្ដុះបណ្ដាល ការរៀន ការបង្រៀន ការស្រាវជ្រាវ កម្មសិក្សា និងនវានុវត្តន៍របស់សាកលវិទ្យាល័យ។

## ជំពូកទី២
## ភារកិច្ចនិងរចនាសម្ព័ន្ធរបស់ ស.ភ.ន.ទ.ស.

**មាត្រា២ .-**

**ស.ភ.ន.ទ.ស.** មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកា
- អប់រំបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ស្របតាមបេសកកម្មរបស់ **ស.ភ.ន.ទ.ស.**
- សិក្សាស្រាវជ្រាវខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិនិងភាសាបរទេសឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំអភិវឌ្ឍកម្មវិធីសិក្សាស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជានិងឆ្លើយតបចំពោះគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំស្របតាមតម្រូវការនិងបរិវត្តកម្មវិធីឌីជីថល
- សហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូពាក់ព័ន្ធ ដើម្បីអភិវឌ្ឍការសិក្សា ការស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងនវានុវត្តន៍
- ផ្តល់យោបល់ដល់ភាគីពាក់ព័ន្ធដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សហគមន៍ តាមការចាំបាច់
- គ្រប់គ្រងបុគ្គលិក និស្សិត ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ **ស.ភ.ន.ទ.ស.**
- បណ្តុះបណ្តាលវគ្គខ្លីឬមធ្យម តាមការចាំបាច់
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**ស.ភ.ន.ទ.ស.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង
- មហាវិទ្យាល័យរដ្ឋបាលសាធារណៈ
- មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា
- សាលាក្រោយបរិញ្ញាបត្រ ថ្នាក់ស្មើមហាវិទ្យាល័យ
- មជ្ឈមណ្ឌលស្រាវជ្រាវ ថ្នាក់ស្មើមហាវិទ្យាល័យ។

មហាវិទ្យាល័យនីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យនិងមានព្រឹទ្ធបុរសរងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលាក្រោយបរិញ្ញាបត្រ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យនិងមាននាយករងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យនិងមាននាយករងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ស.ភ.ន.វ.ស**. អាចស្នើសុំបង្កើតមហាវិទ្យាល័យ មជ្ឈមណ្ឌល និងវិទ្យាស្ថានថ្មីបន្ថែម តាមការចាំបាច់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **ស.ភ.ន.វ.ស**. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពចំណុះផ្សេងៗទៀតនៃ **ស.ភ.ន.វ.ស**. ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

**ស.ភ.ន.វ.ស**. មានសិទ្ធិប្រើត្រានិងរូបសញ្ញាដាច់ដោយឡែក ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

**ស.ភ.ន.វ.ស**. អាចស្នើសុំបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ ក្រុមប្រឹក្សា និងគណៈកម្មការនានា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## ភារកិច្ចរបស់មហាវិទ្យាល័យនិងថ្នាក់ប្រហាក់ប្រហែល

**មាត្រា៧ .-**

មហាវិទ្យាល័យនីតិសាស្ត្រ មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបរិញ្ញាបត្រនីតិសាស្ត្រ
- រៀបចំចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍមហាវិទ្យាល័យ
- រៀបចំគម្រោងផែនការថវិការបស់មហាវិទ្យាល័យ
- អភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិនិងតម្រូវការទីផ្សារការងារ
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអភិវឌ្ឍមហាវិទ្យាល័យ
- អញ្ជើញអ្នកវិជ្ជាជីវៈច្បាប់ជាតិ និងអន្តរជាតិធ្វើសន្និសីទ សិក្ខាសាលា បាឋកថា ដើម្បីបង្កើនសមត្ថភាពនិងចែករំលែកបទពិសោធដល់សាស្ត្រាចារ្យនិងនិស្សិតផ្នែកនីតិសាស្ត្រ
- រៀបចំនិងដឹកនាំទស្សនកិច្ចសិក្សានិស្សិតតាមស្ថាប័នរដ្ឋនិងតាមសាលាជម្រះក្តី ដើម្បីផ្សារភ្ជាប់ផ្នែកទ្រឹស្តីនិងការអនុវត្តជាក់ស្តែង
- រៀបចំសវនាការប្រឌិតសម្រាប់និស្សិតដើម្បីពង្រឹងនិងបង្កើនសមត្ថភាពក្នុងប្រព័ន្ធយុត្តាធិការ
- ធ្វើផែនការជ្រើសរើសនិស្សិតនិងផែនការតម្រូវការសាស្ត្រាចារ្យ
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យ

- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា៨ .-**

មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍ បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ បរិញ្ញាបត្រគណនេយ្យ បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច និងបរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច
- រៀបចំគម្រោងផែនការថវិការបស់មហាវិទ្យាល័យ
- គ្រប់គ្រងមន្ត្រីរាជការ សាស្ត្រាចារ្យ និងបុគ្គលិករបស់មហាវិទ្យាល័យ
- ធ្វើផែនការជ្រើសរើសនិស្សិតនិងផែនការតម្រូវការសាស្ត្រាចារ្យ
- រៀបចំចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍមហាវិទ្យាល័យ
- អភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិនិងតម្រូវការទីផ្សារការងារ
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអភិវឌ្ឍមហាវិទ្យាល័យ
- ពង្រឹងនិងបង្កើនកម្មវិធីផ្លាស់ប្តូរសាស្ត្រាចារ្យជាតិនិងអន្តរជាតិ ដើម្បីចែករំលែកបទពិសោធបង្រៀននិងស្រាវជ្រាវ
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា៩ .-**

មហាវិទ្យាល័យរដ្ឋបាលសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបរិញ្ញាបត្ររដ្ឋបាលសាធារណៈ បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ និងបរិញ្ញាបត្រនីតិសាស្ត្រខ្មែរ-ចិន
- អញ្ជើញសាស្ត្រាចារ្យជាតិនិងអន្តរជាតិ ដើម្បីចែករំលែកបទពិសោធនិងផ្លាស់ប្តូរបច្ចេកទេសដល់សាស្ត្រាចារ្យ ទាក់ទងទៅនឹងសកម្មភាពបង្រៀននិងរៀន
- រៀបចំកម្មវិធីប្រកួតប្រជែងសមត្ថភាពនិស្សិតផ្នែកទំនាក់ទំនងអន្តរជាតិនិងរដ្ឋបាលសាធារណៈដោយសហការជាមួយស្ថាប័ននានា
- ដឹកនាំនិស្សិតចុះកម្មសិក្សា ទស្សនកិច្ចសិក្សា ចុះជួយការងារសហគមន៍ និងស្វែងរកការងារសម្រាប់និស្សិត
- រៀបចំគម្រោងផែនការថវិការបស់មហាវិទ្យាល័យ
- រៀបចំចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍមហាវិទ្យាល័យ

- អភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិនិងតម្រូវការទីផ្សារការងារ
- ធ្វើផែនការជ្រើសរើសនិស្សិតនិងផែនការតម្រូវការសាស្ត្រាចារ្យ
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១០.-**

មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលបរិញ្ញាបត្រសេដ្ឋកិច្ចព័ត៌មានវិទ្យានិងបរិញ្ញាបត្រព័ត៌មានវិទ្យា
- បង្កើនសមត្ថភាពផ្នែកព័ត៌មានវិទ្យាដល់មន្ត្រីរាជការ សាស្ត្រាចារ្យ និងបុគ្គលិក
- រៀបចំកម្មវិធីប្រកួតប្រជែងសមត្ថភាពនិស្សិតផ្នែកព័ត៌មានវិទ្យានិងផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអភិវឌ្ឍមហាវិទ្យាល័យ
- រៀបចំគម្រោងផែនការថវិការបស់មហាវិទ្យាល័យ
- រៀបចំចក្ខុវិស័យ បេសកកម្ម ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍមហាវិទ្យាល័យ
- អភិវឌ្ឍកម្មវិធីសិក្សាឱ្យស្របទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- ធ្វើផែនការជ្រើសរើសនិស្សិតនិងផែនការតម្រូវការសាស្ត្រាចារ្យ
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១១.-**

សាលាក្រោយបរិញ្ញាបត្រ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគម្រោងផែនការថវិការបស់សាលាក្រោយបរិញ្ញាបត្រ
- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- បណ្តុះបណ្តាលកម្រិតបណ្ឌិត
- អញ្ជើញសាស្ត្រាចារ្យជាតិនិងអន្តរជាតិ ដើម្បីបង្កើនសមត្ថភាពនិងចែករំលែកបទពិសោធដល់សាស្ត្រាចារ្យនិងនិស្សិតសាលាក្រោយបរិញ្ញាបត្រ
- រៀបចំចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពសម្រាប់អភិវឌ្ឍសាលាក្រោយបរិញ្ញាបត្រ
- គ្រប់គ្រងទិន្នន័យមន្ត្រីរាជការ សាស្ត្រាចារ្យ និងនិស្សិត

- ធ្វើផែនការជ្រើសរើសនិស្សិតនិងផែនការតម្រូវការសាស្ត្រាចារ្យ
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអភិវឌ្ឍមហាវិទ្យាល័យ
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១២ .-**

មជ្ឈមណ្ឌលស្រាវជ្រាវ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគម្រោងផែនការថវិការបស់មជ្ឈមណ្ឌល
- ពង្រឹងសមត្ថភាពស្រាវជ្រាវរបស់បុគ្គលិកអប់រំនិងនិស្សិត
- លើកទឹកចិត្ត គាំទ្រ និងជំរុញសកម្មភាពស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ
- រៀបចំសន្និសីទ សិក្ខាសាលា បាឋកថា និង/ឬវេទិកាពិភាក្សាផ្សព្វផ្សាយពីស្នាដៃស្រាវជ្រាវ និងស្នាដៃពាក់ព័ន្ធផ្សេងៗ
- បង្កើនកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវជាមួយនឹងស្ថាប័នសាធារណៈ ឯកជន និងដៃគូពាក់ព័ន្ធ
- ស្វែងរកប្រភពហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវ
- បោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ
- រៀបចំចក្ខុវិស័យ បេសកកម្ម និងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពសម្រាប់មជ្ឈមណ្ឌល
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រពាក់ព័ន្ធជំនាញផ្សេងៗដែលជាតម្រូវការរបស់សាកលវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា១៣ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនានាចំពោះ **ស.ភ.ន.ឌ.ស**. ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**អង្គការលេខរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

